**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិ**
**គ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**
លេខ: ០៧៣ គជមស.ប្រក

ថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំរកា ព.ស. ២៥៦០
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា គ.ស. ២០១៧

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារសិក្សាដីចំណីឆ្នេរសមុទ្រ និងកោះ នៃតំបន់ឆ្នេរសមុទ្រកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៦៧១ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ មាត្រា ៤ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការបង្កើតក្រុមការងារពិសេស ដើម្បីគាំទ្រការអនុវត្តផ្ទាល់ដល់គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ
- បានឃើញអនុក្រឹត្យលេខ ១២៦៧ អនក្រ.តត ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៤ ស្តីពីការបង្កើតក្រុមការងារអចិន្ត្រៃយ៍ ដើម្បីដោះស្រាយ ជំរុញ និងតាមដានការអភិវឌ្ឍលើកោះរ៉ុង
- យោងប្រកាសលេខ ០៦១ គ.អ.ធ.ក/សសរ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១៦ ស្តីពីការបង្កើតក្រុមការងារជំនួយការបច្ចេកទេសសម្រាប់ក្រុមការងារពិសេស ដើម្បីគាំទ្រការអនុវត្តផ្ទាល់ដល់គណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ
- យោងប្រកាសលេខ ៣១៨ ដនស.ប្រក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារគាំទ្របច្ចេកទេសកសាងប្លង់គោលនិងផែនការប្រើប្រាស់ដីកោះរ៉ុង ក្រុងព្រះសីហនុ
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារសិក្សាដីចំណីឆ្នេរសមុទ្រ និងកោះ នៃតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **ម៉ែន សុផល** | រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ គ.អ.ធ.ក | ប្រធាន |
| ២.ឯកឧត្តម | **យស់ សោមណារ៉ាឌី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣.ឯកឧត្តម | **សាយ ឫទ្ធិសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងជាអគ្គលេខាធិការរង គ.អ.ធ.ក | អនុប្រធាន |
| ៤.ឯកឧត្តម | **ឡោ ដាវុធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ | អនុប្រធាន |
| ៥.ឯកឧត្តម | **ហាក់ សុគសំភារ** | អគ្គលេខាធិការរង គ.អ.ធ.ក | អនុប្រធានអចិន្ត្រៃយ៍ |
| ៦.ឯកឧត្តម | **រ័ត្ន ពិសិដ្ឋ** | អគ្គលេខាធិការរង គ.អ.ធ.ក | សមាជិក |
| ៧.ឯកឧត្តម | **វ៉ាន់ មុនីនាថ** | អគ្គលេខាធិការរង គ.អ.ធ.ក | សមាជិក |
| ៨.ឯកឧត្តម | **សេក សុធីរិទ្ធ** | អគ្គលេខាធិការរង គ.អ.ធ.ក | សមាជិក |
| ៩.ឯកឧត្តម | **នី ផល្លី** | អគ្គលេខាធិការរង គ.អ.ធ.ក | សមាជិក |
| ១០.ឯកឧត្តម | **លឹម អ៊ីវ** | អគ្គលេខាធិការរង គ.អ.ធ.ក | សមាជិក |
| ១១.ឯកឧត្តម | **ហាក់ ប៊ុណ្ណាក់** | ទីប្រឹក្សា | សមាជិក |

| | | | |
|---|---|---|---|
| ១២.ឯកឧត្តម | **កែវ កុសល** | ទីប្រឹក្សា | សមាជិក |
| ១៣.លោក | **ខ្វិន សុទ្ធារិទ្ធិ** | ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១៤.លោក | **ម៉ៅ ត្រឹម** | ប្រធានផ្នែករៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ១៥.លោក | **ជា ឡេង** | ប្រធានផ្នែកគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ | សមាជិក |
| ១៦.លោក | **ជុក ជំនោរ** | ប្រធានផ្នែកគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ | សមាជិក |
| ១៧.លោក | **សុគន្ធ ណារ៉ុង** | ប្រធានផ្នែកទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការ | សមាជិក |
| ១៨.លោក | **ម៉ិល តិរក្សា** | អនុប្រធានផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម | សមាជិក |
| ១៩.លោក | **រ៉ុយ ម៉ា** | អនុប្រធានផ្នែកអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយនិងព័ត៌មានវិទ្យា | សមាជិក |
| ២០.លោក | **ស៊ាង គឹមលាង** | អនុប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ២១.លោក | **ហោង ជីវី** | ប្រធានការិយាល័យសិក្សា | សមាជិក |
| ២២.លោក | **ស្ងួន យុទ្ធីរក្សា** | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ២៣.កញ្ញា | **ផល ជាណា** | អនុប្រធានការិយាល័យនគរូបនីយកម្ម | សមាជិកា |
| ២៤.លោក | **សាន ស៊ីវត្ថា** | អនុប្រធានការិយាល័យបច្ចេកទេស | សមាជិក |
| ២៥.លោក | **សេក ចំនួមុនី** | អនុប្រធានការិយាល័យស្ថាបត្យកម្ម | សមាជិក |
| ២៦.លោក | **យី វុត្ថា** | អនុប្រធានការិយាល័យវិស្វកម្ម និងកិច្ចការតម្លៃ | សមាជិក |
| ២៧.លោក | **ផល សុគំណា** | ស្ថាបត្យករនៃនាយកដ្ឋាននគរូបនីយកម្ម | សមាជិក។ |

**ប្រការ ២ .-**

ក្រុមការងារសិក្សាដីចំណីឆ្នេរសមុទ្រ និងកោះ នៃតំបន់ឆ្នេរសមុទ្រកម្ពុជាមានតួនាទីនិងភារកិច្ច ដូចតទៅ÷

-សម្របសម្រួល និងសហការជាមួយគណៈកម្មាធិការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាថ្នាក់ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការសិក្សាដីចំណីឆ្នេរសមុទ្រ និងកោះនៃតំបន់ឆ្នេរសមុទ្រកម្ពុជា

-គាំទ្របច្ចេកទេសក្នុងការសិក្សាដីចំណីឆ្នេរសមុទ្រ និងកោះនៃតំបន់ឆ្នេរសមុទ្រកម្ពុជា ស្របតាមនីតិវិធី និងឯកសារគតិយុត្តជាធរមាន

-រៀបចំសិក្ខាសាលានិងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន តំណាងសហគមន៍ តំណាងប្រជាពលរដ្ឋនិងភាគីពាក់ព័ន្ធដែលទាក់ទងនឹងការសិក្សាដីចំណីឆ្នេរសមុទ្រ និងកោះនៃតំបន់ឆ្នេរសមុទ្រកម្ពុជា

-ជំរុញនិងសម្របសម្រួលដំណើរការស្នើសុំការអនុម័តលើលទ្ធផលនៃការសិក្សាដីចំណីឆ្នេរសមុទ្រ និងកោះ នៃតំបន់ឆ្នេរសមុទ្រកម្ពុជា ក្រោយពេលបញ្ចប់ការសិក្សា

-បំពេញការងារចាំបាច់ផ្សេងៗទៀត ដែលថ្នាក់នាំប្រគល់ជូន ដើម្បីសម្រេចបាននូវលទ្ធផលនៃការសិក្សាដីចំណីឆ្នេរសមុទ្រ និងកោះនៃតំបន់ឆ្នេរសមុទ្រកម្ពុជា។

**ប្រការ ៣ .-**

សមាជិកក្រុមការងារទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានតាមការប្រគល់សិទ្ធិពីប្រធាន។ សមាជិកក្រុមការងារមានសិទ្ធិប្រើប្រាស់មន្ត្រីរាជការក្រោមឱវាទឱ្យជួយបំពេញការងារតាមការចាំបាច់។

**ប្រការ ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែប និងខេត្តកោះកុង អគ្គលេខាធិការ គ.អ.ធ.ក អគ្គលេខាធិការ គ.ជ.ន.ជ ប្រធានគ្រប់នាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជា សុផារ៉ា

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងបរិស្ថាន
- រដ្ឋបាលខេត្តព្រះសីហនុ
- រដ្ឋបាលខេត្តកំពត
- រដ្ឋបាលខេត្តកែប
- រដ្ឋបាលខេត្តកោះកុង
- ដូចប្រការ ៤
- ឯកសារ កាលប្បវត្តិ